**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២២៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដី ចំនួន ០៥ ទីតាំង ទំហំសរុប ៥៥.៧៦២ ម$^2$ (ហាសិបប្រាំពាន់ ប្រាំពីររយហុកសិបពីរ ម៉ែត្រក្រឡា) ស្ថិតក្នុងសង្កាត់ពញាពន់ សង្កាត់ពន្សាំង និងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលត្រូវបានកំណត់ដោយអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ក្នុងនោះរួមមានៈ

- ទីតាំងទី១. មានផ្ទៃដី ទំហំ ១០.៦៧៨ ម² (ដប់ពាន់ ប្រាំមួយរយចិតសិបប្រាំបី ម៉ែត្រក្រឡា) ស្ថិតនៅភូមិធំត្បូង សង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ)។
- ទីតាំងទី២. មានផ្ទៃដី ទំហំ ១៣.៤៧៨ ម² (ដប់បីពាន់ បួនរយចិតសិបប្រាំបី ម៉ែត្រក្រឡា) ស្ថិតនៅភូមិបឹង សង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ)។
- ទីតាំងទី៣. មានផ្ទៃដី ទំហំ ១៧.៣៩៥ ម² (ដប់ប្រាំពីរពាន់ បីរយកៅសិបប្រាំ ម៉ែត្រក្រឡា) ស្ថិតនៅភូមិបឹង សង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ)។
- ទីតាំងទី៤. មានផ្ទៃដី ទំហំ ៤.៨៥៨ ម² (បួនពាន់ ប្រាំបីរយហាសិបប្រាំបី ម៉ែត្រក្រឡា) ស្ថិតនៅភូមិកោះរង្សៀង សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យនេះ)។
- ទីតាំងទី៥. មានផ្ទៃដី ទំហំ ៩.៣៥៣ ម² (ប្រាំបួនពាន់ បីរយហាសិបបី ម៉ែត្រក្រឡា) ស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យនេះ)។

**មាត្រា ២:** ត្រូវបានធ្វើប្រទានកម្មផ្ទៃដី ចំនួន០៥ទីតាំង ទំហំសរុប ៥៥.៧៦២ ម² (ហាសិបប្រាំពាន់ ប្រាំពីររយហុកសិបពីរ ម៉ែត្រក្រឡា) ស្ថិតក្នុងសង្កាត់ពញាពន់ សង្កាត់ពន្សាំង និងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ខាងលើ ជាកម្មសិទ្ធិជូនលោក ម៉ៅ នីរ៉ូត លោក សុខ ចំរើន និងលោក វុត្ថា ដូនេ ដោយពន្ធ និងអាករផ្សេងៗ ជាបន្ទុករបស់រដ្ឋ។

**មាត្រា ៣:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ .សុក្រ...៣..រោច. ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...៤..... ខែ.សីហា.... ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា៤*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ២២៧ អនក្រ.បក ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ២០២៣**
**ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 479330.071 | 1289469.055 | 3 | 479496.326 | 1289521.069 |
| 2 | 479340.761 | 1289542.645 | 4 | 479490.939 | 1289461.170 |

**ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ២២៧ អនក្រ.បក ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ២០២៣**
**ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 476807.688 | 1287963.202 | 7 | 476671.065 | 1287857.558 |
| 2 | 476808.351 | 1287962.653 | 8 | 476742.931 | 1287876.293 |
| 3 | 476812.820 | 1287961.182 | 9 | 476737.904 | 1287917.099 |
| 4 | 476927.321 | 1287951.582 | 10 | 476751.587 | 1287919.114 |
| 5 | 476929.306 | 1287951.304 | 11 | 476808.625 | 1287925.536 |
| 6 | 476932.797 | 1287885.761 | | | |

**ឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យលេខ២២៧ អនក្រ.បក ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ២០២៣**
**ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 476536.611 | 1287679.799 | 7 | 476676.462 | 1287722.256 |
| 2 | 476534.105 | 1287713.909 | 8 | 476646.636 | 1287834.847 |
| 3 | 476570.810 | 1287719.340 | 9 | 476745.963 | 1287845.547 |
| 4 | 476574.018 | 1287715.115 | 10 | 476759.058 | 1287709.159 |
| 5 | 476599.391 | 1287717.863 | 11 | 476680.227 | 1287690.790 |
| 6 | 476646.225 | 1287721.784 | | | |

**ឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យលេខ២២៧ អនក្រ.បក ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ២០២៣**
**ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 476793.968 | 1285174.121 | 5 | 476831.604 | 1285057.537 |
| 2 | 476794.730 | 1285187.058 | 6 | 476819.140 | 1285055.076 |
| 3 | 476893.353 | 1285077.701 | 7 | 476812.823 | 1285139.411 |
| 4 | 476892.167 | 1285073.699 | | | |

**ឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យលេខ២២៧ អនក្រ.បក ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ២០២៣**
**ស្តីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| 1 | 476841.804 | 1284892.918 | 6 | 476834.316 | 1285045.841 |
| 2 | 476838.585 | 1284913.371 | 7 | 476885.124 | 1285059.400 |
| 3 | 476835.089 | 1284935.230 | 8 | 476896.905 | 1284910.162 |
| 4 | 476820.054 | 1285036.515 | 9 | 476844.653 | 1284893.531 |
| 5 | 476819.115 | 1285042.840 | | | |